# ប្រវត្តិអាចារ្យក្នុងប្រទេសកម្ពុជា



ស៊ិន សុវណ្ណាធិ

## រូបក្របខាងមុខនៃសៀវភៅ

១-អាចារ្យ ម៉ី-ឆាង,២-ទិន-ហ្វួត,៣-ឈឹម-ស៊ុមន៍, ៤-ញ៉ូង-សឿង, អាចារ្យ៤រូប នេះ បាំគោរពព្រះបរមសារីរិកធាតុ ក្បែររថយន្តបុស្បុក ដែលស្អិតស្អាង សម្រាប់តម្កល់ព្រះបរមសារីរិកធាតុ ដើម្បីដង្ហែចេញពីអាកាសយានដ្ឋាន ពោធិចិនតុងមកក្រុងភ្នំពេញ។ ដកចេញពីសៀវភៅ ព្រះរាជជីវប្រវត្តិ ពិស្តារ និងកាព្យលោកធម៌។

ភ្នំពេញ,រក្សាសិទ្ធិគ្រប់យ៉ាង

ISBN:...........................

# សារបណ្ណា

ប្រវត្តិអាហារក្នុងប្រទេសកម្ពុជា

**លក្ខណៈទូទៅ:**

របៀបត្រណមនៃអាហារ និងអ្នកម្ចាស់កម្មវិធីតាមស្រុកនីមួយៗ

-បញ្ញត្តសព្ទពាក្យថា អាហារ

-អង្គរបស់អាហារ មាន៧ យ៉ាង

-អាហារក្នុងសម័យពុទ្ធកាល

បណ្ឌិតាហារសម័យមហានគរ(គ្រឹស្តសវត្សរ៍ទី៩ ដល់១៤)

ក្នុងគម្ពីរពុទ្ធសាសនាបានបញ្ញត្តិថា អាហារ មាន ៥ ប្រភេទ

ក-ខសង្កេត និងការស្រាវជ្រាវ

ខ-ខសង្កេតនិងការស្រាវជ្រាវតាមសិលាចារឹកខ្លះៗ

-ឯកសារយោង

ឧបសម្ព័ន្ធះសិលាចារឹកស្តុកកក់ធំជាភាសាសំស្ក្រឹត,សិលាចារឹកជយនន្ទ,

# និវេទនកថា

បច្ចុប្បន្នកាលនេះមានអ្នកស្រាវជ្រាវច្រើនណាស់ដែលចង់ដឹងអំពីប្រវត្តិរឿងរ៉ាវផ្សេងៗក្នុងសម័យអតីតកាល ។ ប្រវត្តិរឿងទាំងអស់នោះមានជាអាទិ៍ ប្រវត្តិសាស្ត្រ សង្គមសាស្ត្រ មនុស្សសាស្ត្រ សិលាចារឹកសាស្ត្រ និងភាសាសាស្ត្រ ជាដើម។ ប៉ុន្តែ ការស្រាវជ្រាវនោះ ត្រូវបានបែកចែកទៅជំនាញរៀងៗខ្លួន ។ ដូច្នេះ ប្រវត្តិអាហារក្នុងប្រទេសកម្ពុជា នេះគឺវណ្ណកម្មថ្មីមួយទៀតក្នុងបំណោមស្នាដៃជាច្រើនរបស់ខ្ញុំ ដែលបានបេញផ្សាយរួបមកហើយ ។ ការសិក្សានេះ ខ្ញុំផ្តោតជាសំខាន់ទៅលើបទបញ្ញត្ត នៃពាក្យដែលយើងបានប្រើសព្វថ្ងៃ,ពិធី នៃការធ្វើ,ប្រវត្តិកំណើតនៃអាហារ, ពាក្យប្រដៅទាំងឡាយរបស់អាហារ,និងប្រភេទនៃអាហារ ជាដើម ។ល។ ទាំងអស់នេះហើយជាកម្មវត្ថុដែលខ្ញុំត្រូវនិយាយក្នុងសៀវភៅនេះ។

សូមជម្រាបថា ឯកសារនេះខ្ញុំបានស្រាវជ្រាវតាំងពីឆ្នាំ ២០១១ មកតែដោយសារពេលបង្អៀតពេក ខ្ញុំក៏អាក់ខានទុកមួយដុំបោលសិន ដោយពុំបានស្រាវជ្រាវបន្តទៀតទេ។ ទើបមកដល់ដើមឆ្នាំ២០១៣ មានមិត្តរបស់ជាច្រើនអ្នកចង់បានឯកសារមួយនេះ ទុកជាទីអនុស្សរណៈទៅថ្ងៃមុខ ខ្ញុំក៏សន្យាថា នឹងស្រាវជ្រាវជូន-ប្រគេន ។ ម្យ៉ាងទៀត ខ្ញុំបានរកឯកសារគ្រប់ទីកន្លែង ដើម្បីជាជំនួយដល់ការសរសេររបស់ខ្ញុំផង និងជាសំអាងផង ជាភព្វសំណាងឯកសារនោះមានពិត ប៉ុន្តែ នៅរាយប៉ាយតាមសៀវភៅផ្សេងៗគឺត្រូវទាមទារ ឱ្យខ្ញុំបំណាយពេលដ៏ច្រើនដើម្បីសង្កេតពិនិត្យ, ជាពិសេសច្រើនមាននៅក្នុងសិលាចារឹកខ្មែរយើង, បន្តុំ នៃឯកសារសិលាចារឹកនេះហើយដែលនាំខ្ញុំកង្វល់ឥតឈប់ ពីព្រោះខ្ញុំ មិនបានសិក្សាអក្សរសិលាចារឹក

នោះទេ អ្វីដែលខ្ញុំដកស្រង់ចេញមក គឺជាឯកសារដែលត្រូវបានបកប្រែជាភាសាខ្មែរទំនើប ដោយអ្នកសិលាចារឹកផ្សេងៗ។

ជាអវសានបទ នៃនិវេទនកថានេះ ខ្ញុំសូមសន្មតថា វាគ្រាន់តែជាឯកសារសិក្សាសាកល្បង និងជាតម្រាយផ្លូវដែលមានព្រៃបន្លាតែប៉ុណ្ណោះដូច្នេះ បើមានកំហុសឆ្គងត្រង់ណានោះខ្ញុំអ្នកស្រាវជ្រាវ សូមអភ័យទោសចំពោះលោកអ្នកប្រាជ្ញទាំងឡាយ និងសូមទទួលយកការកែលម្អដោយក្តីសោមនស្ស។

សូមឧទ្ទិសស្នាដៃនេះ ចំពោះព្រះពុទ្ធសាសនាខ្មែរ !

សូមឧទ្ទិសចំពោះប្រជាជាតិខ្មែរទាំងឡាយ សូមបានទទួលនូវប្រយោជន៍អំពីសៀវភៅនេះគ្រប់ៗគ្នា៕

ភ្នំពេញ,ថ្ងៃទី១៥ មករា ២០១៣

**ស៊ិន សុវណ្ណនិ**

សាស្ត្រាចារ្យ អនុបណ្ឌិត

ទស្សនវិជ្ជាពុទ្ធសាសនា

# ប្រវត្តិអាចារ្យក្នុងប្រទេសកម្ពុជា

## លក្ខណៈទូទៅ៖

តាមការសិក្សាស្រាវជ្រាវទៅលើឯកសារនានាដែលស្តីពី ប្រវត្តិអាចារ្យក្នុងប្រទេសកម្ពុជានោះ ដូចជា មិនមានឃើញឯកសារណាមួយ ដែលនិយាយថា កកើតពីរជ្ជកាល ឬ សករាជ នៃព្រះមហាក្សត្រអង្គនេះ ឬ អង្គនោះទេ។ ដូច្នេះ អាចបញ្ជាក់បានថា អាចារ្យនេះ ទំនងជាកើតចេញ មកពីពាក្យ **អ្នកសិក្សា** ។ ម្យ៉ាងទៀត បើផ្អែកតាមមតិអ្នកប្រាជ្ញពុទ្ធសាសនាខ្មែរ លោកយល់ថា **អាចារ្យ** [១] នេះកើតដំណាលគ្នាជាមួយនឹងព្រះពុទ្ធសាស

---

[១]- ក្នុងសទ្ទានុក្រម សំស្ក្រឹត ខ្មែរ បារាំង របស់លោកស្រី បណ្ឌិត សាស្ត្រាចារ្យ ពៅ សាវរស បាននិយាយថា "គ្រួសារទាំងឡាយនៃ "វណៈ" ពីរដែលព្រះបាទជ័យវម៌្មទី៥ ទ្រង់បានបង្កើតឡើង,ហើយព្រះអង្គបានបញ្ញត្ត(ព្រះអាជ្ញា) ដូចតទៅ៖ **"នៅ រូ កុលេ តអ្នក សិ មន អាច តិ បរយ្យាន ហោង នាំ មោក ឱ្យ អាចារយ្យ បតុរាចារយ្យ ប្រេ បរយ្យាន សិក្សា អាយ ឥគរ បិ ប្រេ នាវ្រះ រាការយ្យ"** (IC,II,64,B:9-12) បានសេចក្តីថា "ចំពោះបុរសកុលបុត្រ នៃគ្រួសារទាំងនោះអាចត្រូវនាំមកសិក្សាបាន ដែលត្រូវគេនាំមកនៅចំពោះមុខអាចារ្យ បតុអាចារ្យ ប្រើឱ្យបង្រៀន សិក្សានៅទីក្រុង ក្នុងគុណប្រយោជន៍ ឱ្យបានមកបម្រើក្នុងក្រសួងរាជការ"(ទំព័រ ៣២)។ គាត់បានពន្យល់ទៀតថា ក្នុងព្រាហ្មណ៍ម្នាក់ ជាប្រមុខពិធី ឬ ជាអ្នកបង្រៀនត្រូវយកអត្ថបទសំស្ក្រឹតមកប្រើ ឬ បង្រៀនព្រោះភាសាយាននេះ ជាភាសាដែលគេត្រូវគោរព ជាភាសាកំពូលសម្រាប់មកពន្យល់ និងសិក្សាអំពីវិទ្យាសាស្ត្រនេះ។ សិស្សានុសិស្ស ពុំមានវិជ្ជាដូចសាស្ត្រាចារ្យទេ ដូច្នេះសិស្សត្រូវរៀនភាសានេះ ក្នុងអត្ថបទផ្សេងៗដែលមានពន្យល់ពាក្យរាយជា ជំនួយ ជាភាសាអ្នកស្រុក(ភាសាខ្មែរ) ដូចជាសម័យកាលកន្លងបន្តបន្ទាប់មកខ្មែររៀនធម៌របស់ព្រះពុទ្ធសាសនា ជាភាសាបាលី ដែលមានការប្រែសម្រួលជាភាសាសម្រាយ និងអត្ថាធិប្បាយផង។ ម្យ៉ាងទៀត ព្រាហ្មណ៍ទាំងនោះសម្បូរពោរពេញដោយវិទ្យា "**បណ្ឌិត**" ទាំងនោះប្រៀបដូចជា "មហាសមុទ្រនៃវិទ្យា" ត្រូវបំពេញមុខងារផ្សេងៗក្នុងរង្វង់សង្គម។ គេជួបប្រទះជាទូទៅ "**អាចារ្យ**" យ៉ាងសន្ធឹកសន្ធាប់ ឬ ប្រមុខពិធីដែលគាត់ទាមងនោះមានកិច្ចការយ៉ាងសំខាន់ក្នុងពិធីសាសនា និងពិធីនានាសម្រាប់សង្គម។ ឯនៅក្នុងព្រះបរមរាជវាំង តាំងពីបូរាណកាលមក ពពួកព្រាហ្មណ៍ទាំងនោះមានបែងកម្រិតក្នុងរាជការ ផែនដី

នាតែម្តង។ និយាយដោយឡែកអាចារ្យនេះ បើយោងពីបុរាណកាល មក លោកបែកជា ២ ពួក គឺ៖

១-**លោកអាចារ្យ ឬ ព្រះអាចារ្យ**=មានន័យថា អាចារ្យជាព្រះសង្ឃ។

២-**អ្នកអាចារ្យ**=មានន័យថា អាចារ្យដែលសឹកចេញពីសង្ឃមកធ្វើជាគ្រហស្ថ។ (បទសម្ភាសន៍ ជាមួយលោកសាស្ត្រាចារ្យ យី ធន់[2] កាលពីថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១០)។

ក្នុងន័យខាងលើនេះ អាចបញ្ជាក់បានថា តាមឯកសាររបស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ឈ្មោះ ឧប្បត្តិហេតុនៃព្រះត្រៃបិដកប្រែ មានដាក់តាមក្រុមព្រះសង្ឃីតិកាចារ្យថា៖ អ្នកអាចារ្យ (គ្រហស្ថ) និងព្រះអាចារ្យ (ព្រះសង្ឃ)។ ឧទាហរណ៍: អ្នកអាចារ្យ ប៊ូ ប៉ូ, គិម អាន, នួន ដួង, អ៊ុប រស់, និងលោកអាចារ្យ ឬ ព្រះអាចារ្យ ប៉ែន សុខ,ព្រះអាចារ្យ ហែម ចៀវ,ព្រះអាចារ្យ ឈឹម ស៊ុមន៍, ព្រះអាចារ្យ សូរ ហាយ, ព្រះអាចារ្យ ប៉ាង ខាត់ ជាដើម។ (ឯកសារឧប្បត្តិហេតុ នៃព្រះត្រៃបិដកប្រែ វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ បោះពុម្ពឆ្នាំ១៩៦៩ ទំ.០៥)។

ប៉ុន្តែ បើយោងតាមទស្សនៈអ្នកប្រាជ្ញពុទ្ធសាសនាទូទៅ លោកបានកំណត់ជា ៣ ផ្សេងទៀតថា:

១-**អាចារ្យមង្គល**(អាចារ្យការ)= មានន័យថា គេបេះរកឫកពេលាថ្ងៃល្អ ឬ អាក្រក់សម្រាប់មង្គលការ នៃសកលមហាជន។អាចារ្យប្រភេទនេះ មានរបៀបនៃការស្លៀកពាក់ខុសៗគ្នា។

---

នោះ មានកម្រិតសក្តិ ៤ ប្រភេទ៖ ព្រាហ្មណ៍ឯក, ព្រាហ្មណ៍ទោ, ព្រាហ្មណ៍ត្រីណី, ព្រាហ្មណ៍ចត្វារិ, ដែលហៅថា ចតុរាចារ្យ,ហើយមានប្រធានមួយក្នុងក្រុមនីមួយៗ ដែលមានឈ្មោះហៅថា“អាចារ្យប្រធាន”,។ (ទំព័រ ៣៨-៣៩)

[2] -បច្ចុប្បន្នជា ទីប្រឹក្សាអមព្រះបរមរាជវាំង និងជាគ្រូបង្រៀនអក្សរសាស្ត្រខ្មែរដល់រូបខ្ញុំ។

២-**អាចារ្យភ្លុក**(អាចារ្យបុណ្យខ្មោច=មានន័យថា អាចារ្យដែលចេះពីរបៀបរៀបចំសព ទៅតាមក្បួនខ្នាត។អាចារ្យ ប្រភេទនេះ មានរបៀបនៃការស្លៀកពាក់ខុសៗគ្នា។

៣-**អាចារ្យកណ្ដាល**=មានន័យថា អាចារ្យនៅចន្លោះរវាងអាចារ្យមង្គលនិងអាចារ្យភ្លុក។ **អាចារ្យ** នេះលោកថាមិនមានត្រណមដូចអាចារ្យដទៃៗទៀតទេ។ គឺថាអាចទៅជួយរៀបចំពិធីផ្សេងៗ ដោយមិនមានល័ក្ខ-ក្ខន្ធ។

របៀបត្រណមនៃអាចារ្យ និងអ្នកម្ចាស់កម្មវិធី តាមស្រុកនីមួយៗនៅតាមទីតំបន់ស្រុកទេសផ្សេងៗគេសង្កេតឃើញ មានអាចារ្យ និងអ្នករៀបចំកម្មវិធីមួយចំនួនដែលមានត្រណមយ៉ាងតឹងរ៉ឹង និងប្រកាន់ទស្សនៈក្នុងការអនុវត្តនូវគោលការណ៍របស់ខ្លួន។ ឧទាហរណ៍ ដូចជា អាចារ្យការគេដាច់ខាតមិនអញ្ជើញទៅរៀបចំពិធីបុណ្យសពនោះទេ។ឯ អាចារ្យយោគីក៏គេដាច់ខាតមិនអញ្ជើញទៅរៀបចំបុណ្យសពឡើយ។ ត្រណមទាំងអស់នេះ កើតឡើងទៅតាមទស្សនៈរបស់គ្រូបាអាចារ្យរៀងៗខ្លួន។ មិនមានគម្ពីរក្នុងព្រះពុទ្ធសាសនាណាមួយ និយាយដល់បំណុចទាំងនេះឡើយ។សូមសួរថា តើហេតុអ្វីបានជាព្រះពុទ្ធមិនបញ្ញត្តិវិន័យមកថា មានលោកសង្ឃសម្រាប់សូត្រមន្តការ និងមានលោកសង្ឃសម្រាប់សូត្របុណ្យសពផង? ឃើញតែព្រះសង្ឃឱ្យតែទាយកនិមន្តទៅទាំងអស់ ។ តើការនិមន្តទៅនោះមានចង្រៃដល់ពិធីរបស់គេទេ? សូមបញ្ជាក់ថា ការតមត្រណមនេះមិនមែនជាព្រះពុទ្ធដីកាឡើយ វាជាទស្សនៈ ឬ ជាការយល់ឃើញរៀងៗខ្លួន។ ដូច្នេះ ឱ្យតែអាចារ្យ អាចដឹកនាំគេធ្វើបានទាំងអស់ព្រោះអាចារ្យ មានន័យ

ជា អ្នកសិក្សាចេះដឹង, អ្នកចង្អុលបង្ហាញ[៣]។ ឯ អាចារ្យមង្គលការ គេមានត្រណមខុសពីអាចារ្យបុណ្យសពទាំងស្រុង ដោយគេសំអាងថា អាចារ្យមង្គលការ ជាអាចារ្យសិរីសួស្តី, សុភមង្គល, សប្បាយរីករាយ។ បំណែកអាចារ្យបុណ្យសព ជាអាចារ្យអមង្គល, អាចារ្យក្រៀមក្រំ, អាចារ្យអនិច្ចា, មិនមានសិរីសួស្តីទេ ដូច្នេះហើយបានជាគេ មិនយកអាចារ្យបុណ្យសពទៅឱ្យរៀបចំមង្គលការរបស់គេ។ អាចារ្យការនេះទៀតសោត កន្លែងខ្លះគេសម្គាល់លើលក្ខណៈ៤យ៉ាងគឺៈ

**១-ធ្លាប់បានបួសជាព្រះសង្ឃ,**

**២-ជាអ្នកស្រាវជ្រាវ,**

**៣-ប៉ិនប្រសព្វខាងវោហារសាស្ត្រ,**

**៤-មានគុណសម្បត្តិខាងរៀបចំពិធី។**

ឯ ការតមត្រណមរបស់គេ គឺៈ វៀរបាកការបរិភោគសុរា,វៀរបាកការពោលពាក្យកុហក, និងប្រកាន់ពាក្យសច្ចៈទៀងត្រង់ ជាដើម។ (យោងតាមបទសម្ភាសន៍ ជាមួយនឹងលោកអាចារ្យមង្គលការនានា)។

---

[៣] -គ្រប់កិច្ចការទាំងឡាយលោកអាចារ្យអាចដឹកនាំ និងពន្យល់អំពីទំនៀមទម្លាប់ផ្សេងៗក្នុងពិធីនោះទៅតាមលទ្ធភាពដែលខ្លួនបានចេះដឹង មិនមែនមិនចេះហើយអួតខ្លួនថាចេះនោះទេ។ បច្ចុប្បន្ននេះ បើតាមការសង្កេតឃើញថា មានអស់លោកមួយចំនួនហាក់ដូចជា ចាប់អារម្មណ៍នឹងរឿងនេះខ្លាំងណាស់ រហូតដល់ដល់មានទស្សនៈថា ការធ្វើជាអាចារ្យ ឬក៏ចាប់យកអាជីពនេះក៏ល្អម្យ៉ាងដែរ ពីព្រោះទៅថ្ងៃមុខអាចមានបាន។ កាលបើមានទស្សនៈបែបនោះ តាមយោបល់របស់ខ្ញុំយល់ថា គួរកុំប្រព្រឹត្តល្អជាជាង ព្រោះថា នាំឱ្យមានជំនៀលក្នុងសង្គមទៅថ្ងៃអនាគត។ ដូច្នេះខ្ញុំបានជម្រាបមកហើយថា និយមន័យពិតរបស់អាចារ្យ មិនមែនដូចទស្សនៈខាងលើនេះទេ។ សូមអភ័យទោសកុំខឹងនឹងខ្ញុំ

យោងតាមការសិក្សាស្រាវជ្រាវ អំពីពិធីត្រណមរបស់ព្រាហ្មណ៍ ក្នុងប្រទេសកម្ពុជា បានឱ្យដឹងថា ពួកព្រាហ្មណ៍តាមធម្មតា តែងតែកាន់ត្រណមវៀរចាកការបរិភោគសាច់សត្វជំពូកខ្លះ រហូតអស់មួយជីវិត ដូចមានកំណត់ក្នុងសាស្ត្រាច្បាប់ព្រះកេតុមាលា គឺសាច់គោ,រមាំង,ប្រើស,ក្របីឃ្លៀប,ជ្រូកព្រៃ,ក្រពើ,ទន្សង,ទន្សោង,មាន់ស្រុក, ពស់,កង្កែប,ក្តាម,អន្ទង់,ត្រីទីពោ,ត្រីក្រាយ,ត្រីសណ្តាយ,ត្រីផ្ទក់,លៀស,ខ្ចៅ,គ្រំៗតែព្រាហ្មណ៍ស្រុកខ្មែរក្នុងសម័យនេះ ឃើញដូចជា មិនសូវកាន់ឱ្យបានតឹងទៅតាមវិន័យនេះប៉ុន្មានៗក្នុងឱកាសបួលហោពិធីម្តងៗត្រូវតែកាន់ ត្រណមយ៉ាងតឹងជាធម្មតា គឺកាន់សីលវៀរចាកសេពមេថុន, វៀរចាកបរិភោគសាច់សត្វគ្រប់ជំពូក, កំណត់ឱ្យបរិភោគបាយលាយនឹងល្ងលីង, អំបិលលីង, សម្លសាប, ដែលស្លដោយត្រឡាច ល្ពៅជាបន្លែដាក់ខ្ទិះដូង និងស្ករបន្តិចផង សម្តេចតសីភទ្ទាធិបតី(ម៉ាំង)ថា បើស្លឱ្យត្រូវមែនទែនត្រូវលាយមីសួរ និងពពុះសណ្តែកផងៗ លុះចេញពីពិធីហើយ ទើបបរិភោគតាមធម្មតាបានៗ (ព្រះរាជពិធីទ្វាទសមាស ប្រាក់ព្រះនង្គ័ល បោះពុម្ពឆ្នាំ២០០៤ ទំ.១៨-១៩)ៗ

ការលើកមកបង្ហាញប៉ុណ្ណេះ ចង់បញ្ជាក់ថា ពួកគេមានក្បួនច្បាប់របស់ប៉ុនគេ ច្បាស់លាស់តាំងពីបុរាណកាលមក តែបំពោះការតមត្រណមរបស់អាចារ្យមង្គលការ និងអាចារ្យបុណ្យសពវិញ មិនមានឃើញឯកសារណាជាអំនះអំណាងឡើយៗ ដូច្នេះ តាមការសន្និដ្ឋាន ទំនងប្រហែលជាតមតាមរបៀបពួកព្រាហ្មណ៍ដែរៗ ប៉ុន្តែ គ្រាន់តែមានលក្ខណៈ ម៉្យាងខុសគ្នាខាងការអនុវត្តពិធី និងការតមអាហារតែប៉ុណ្ណោះ ។

# បញ្ញត្តសព្ទ ពាក្យថា អាចារ្យ

បើយោងតាមភាសាបាលី ថា **អាចរិយ** មកពី (អា-បុព្វបទ + ចរ-ធាតុ+ណ-បច្ច័យ+ឥ-អាគម) ប្រែថា អ្នកប្រព្រឹត្តនូវអំពើជាប្រយោជន៍ដល់សិស្ស ឬ អ្នកដែលសិស្សត្រូវប្រព្រឹត្តដោយអើពើ ឬ ដោយសេចក្ដីគោរព (អាចារ្យ), វិគ្គហៈថា **សិស្សានំ ហិតមាចរតីតិ> អាចរិយោ, អាទរេន ចរិតព្វោតិ វា >អាចរិយោ។** (ព្រះគ្រូសាសនសោភ័ណ កឹម តូវ,បទានុក្រមធម្មបទ ភាគ១ បោះពុម្ពលើកទី១ ឆ្នាំ១៩៥០ ទំ.២៦២ ដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ,ប្រទេសកម្ពុជា)។

-**អាចារ្យ**(ācārya)= ១-អ្នកបង្រៀន, គ្រូ, អ្នកប្រមុខពិធីតាមសាសនា និងតាម «មន្ត្រ:» ផងដែរ, និងជាអ្នកបង្រៀនអ្នកដទៃ ឱ្យបានក្លាយទៅជា «គ្រូ»។ ២-មានករណីពិសេសមួយ គឺ ការប្រើរួមបូលគ្នានៅកម្ពុជា: «អាចារ្យ» ដែលប្រើនៅក្នុងព្រាហ្មណ៍សាសនា និងព្រះពុទ្ធសាសនាផ្នែកមហាយាននោះ និងបន្តមកព្រះពុទ្ធសាសនាផ្នែកថេរវាទទៀត។ រីពាក្យ «អាចារ្យ» ខាងពុទ្ធសាសនា ជាប្រមុខពិធីក្នុងវត្ត និងមានភារកិច្ចក្នុងពិធីបកស្រាយផ្នែកធម៌រវាងព្រះសង្ឃផង និងពុទ្ធបរិស័ទផង។

-**អាចារ្យប្រធាន:**(ācāryaadhāna)=១-មេក្រុមអាចារ្យ,បញ្ជាក់ប្រើញឹកញាប់ណាស់ នៅក្នុងស្ថាប័ននៃពិធីផ្សេងៗ។២-នៅក្នុងស្ថាប័ន គឺពាក្យសម្គាល់មេនានានៃក្រុមធំៗទាំង ៤ របស់អាចារ្យ ដែលហៅថា «ចតុរាចារ្យ»។ (សទ្ទានុក្រម សំស្ក្រឹត ខ្មែរ បារាំង, លោកស្រីបណ្ឌិត សាស្ត្រាចារ្យ ពៅ សាវរស,ឆ្នាំ២០១៣, ទំ.១៦៤-១៦៥,បណ្ណាគារអង្គរ)។

យោងតាមវចនានុក្រមខ្មែរ (របស់សម្ដេច ជួន ណាត) ថា៖

**អាចារ្យ** មានន័យថា អ្នកប្រដៅ ឬ ហាត់មារយាទ, អ្នកប្រព្រឹត្តល្អ, អ្នកកាន់ត្រឹមត្រូវ, អ្នកដែលសិស្សត្រូវគោរព, អ្នកធ្វើប្រយោជន៍ដល់សិស្ស, អ្នកបង្រៀនបំណោះគេ, គ្រូ, គ្រូបង្រៀន ។ ឧទាហរណ៍: សិស្សមានវិជ្ជាដោយសារអាចារ្យខំប្រឹងបង្រៀន។ សមដូចសុភាសិតក្នុងមង្គលត្ថទីបនី ថា "គ្រូអាចារ្យ ជាអ្នកបង្ហាញផ្លូវ"។ បុរាណសុភាសិតពោលថា "អ្នកដើរមុខបេះបង់បោយ អ្នកដើរក្រោយបេះរែកពុន"។ "សន្តានថ្លៃ វិន័យល្អ"; ភាសិតខ្ញុំ។ ម្យ៉ាងទៀត " គ្រូ (អាចារ្យ) ជាទក្ខិណេយ្យបុគ្គលរបស់សិស្ស"។ (មង្គលលត្ថទីបនី)

<u>ភាសិតបុរាណ</u>

-អ្នកដឹងគុណគ្រូ បង្កើតអភិវូ អ្នកហោងស្មើម្ដាយ
នឹងបានរួចទុក្ខ ផុតក្ដីអន្តរាយ អ្នកគ្រូស្មើម្ដាយ
បង្កើតក្ដីច្បាប់ ។

តាមសេចក្ដីក្នុង **គម្ពីរអង្គុតរនិកាយ ទសកនិបាត** បុគ្គលដែលគួរគោរពបូជា មិនត្រូវនរណាប្រមាថមើលងាយនោះមាន ១០ ពួកដើម្បីឲ្យស្រួលដល់ការចេះចាំផង យើងសូមដកស្រង់ទាំងបាលីគាថាមកទុកក្នុងទីនេះ ។

**ពុទ្ធោ បច្ចេកពុទ្ធោ ច អរហា អគ្គសាវកោ**
**មាតាបិតា គរុ សត្ថា ទាយកោ ធម្មទេសកោ**
**បណ្ឌិតតេហិ ឥមេ ទស ន ទុព្ភន្តិ ជានិយា។**

ព្រះពុទ្ធ១, ព្រះបច្ចេកពុទ្ធ១, ពួកព្រះអរហន្ត១, អគ្គសាវ័ក១, មាតា១, បិតា១,**គ្រូ១,សាស្ត្រាចារ្យ១**,ទាយកគឺអ្នកផ្តល់អាមិសឲ្យ១, អ្នកសម្តែងធម៌១, បណ្ឌិតគួរជ្រាបថា បុគ្គលទាំង ១០ ពួកនេះ គឺនរណាមួយប្រទូស្តមិនបាន ។

## អង្គរបស់អាចារ្យ មាន៧ យ៉ាងគឺ[៤]

១-ជាទីស្រឡាញ់របស់សិស្សានុសិស្សទាំងឡាយ,

២-ត្រូវមានចិត្តអំណត់អត់ធន់ គួរជាទីគោរពបូជា
នៃសិស្សទាំងឡាយ,

៣-ជាគំរូដ៏ល្អសម្រាប់សិស្សទាំងឡាយ,

៤-ជាអ្នកផ្តល់ដំបូន្មានដ៏ល្អសម្រាប់សិស្សទាំងឡាយ,

៥-ត្រូវអត់ឱនរាល់ទោសកំហុសដែលគួរអត់ឱនបាន,

៦-ជាអ្នកប្រៀនប្រដៅប្រកបដោយហេតុផលនិងមានប្រយោជន៍,

៧-ជាអ្នកបង្ហាញផ្លូវសុចរិតនិងទៀងត្រង់ដល់សិស្សទាំងឡាយ។

## អាចារ្យក្នុងសម័យពុទ្ធកាល

ក្នុងសតវត្សរ៍ទី៦ មុនគ្រឹស្តសករាជ មានសាស្តាចារ្យសំខាន់ៗ ជាច្រើនដែលឧប្បត្តិឡើងក្នុងលោក មានដូចជាៈ

ប្រទេសក្រិច គឺប៉ារ៉ា-មិនិដេស (Para-mendes), និងឯមពីដូគ្លេស (Embedocles) ប្រទេសអ៊ីរ៉ង់ មាន សារាធុសត្រា(Zar athustra),ប្រទេសចិន មាន ឡៅ ប៊ី (Lao Tyu), និង ខុង ជឺ (Comfucius),ប្រទេសឥណ្ឌា មាន

---

[៤]-ឯកសារក្រសួងធម្មការ និងសាសនា ឆ្នាំ ២០១០,ដោយលោក រ៉ាយ វិបុល។

ព្រះពុទ្ធនៃយើង និងគ្រូទាំង៦ គឺ៖ *១-បូរណកស្សបៈ ២-មក្ខលិគោសាល ៣-អជិតកេសកម្ពល ៤-បកុធកច្ចាយន ៥-និគ្គណ្ឋនាដបុត្រ ៦-សញ្ជ័យបរិព្វាជក។* គ្រូទាំង ៦ នេះជាសាស្តាចារ្យមានគាល្បីល្បាញក្នុងលោក និងមានកូនសិស្សគោរពស្រឡាញ់រាប់អានដ៏ច្រើនលើសលប់។ ( នៅ សាខន ឯកសារជាភាសាខ្មែរ ប្រវត្តិសាស្ត្រនៃពុទ្ធសាសនា នៅប្រទេសឥណ្ឌា បោះពុម្ពឆ្នាំ១៩៦៤ នៅបាងកក ឆ្នាំ២០០៦ លើកទី១ នៅកម្ពុជា ភ្នំពេញ ទំព័រ៤៨)។ នៅសម័យពុទ្ធកាល មានមុខវិជ្ជាបំនួន១៨ ឯកទេស ហើយការសិក្សាសម័យនោះ មានការបែងចែកទៅតាមឋានៈក្នុងសង្គមប្រទេសឥណ្ឌា។ សូមបញ្ជាក់ថា **អាចារ្យ** ដែលវ័យចំណាស់ជាងគឺ អាឡារតាបស,និងឧទកតាបស ដែលជាគ្រូរបស់ព្រះពុទ្ធ ផ្ទាល់ធ្លាប់រស់នៅសិក្សាជាមួយ។ ហើយ ព្រះអាចារ្យ ទាំងពីររូបនេះ គឺជាបណ្ឌិតដ៏មានឥទ្ធិពលក្នុងសង្គមឥណ្ឌា នាសម័យកាលនោះ។ (ឯកសារដូចខាងលើទំ.១៣០)។ ខាងក្រោយមកមាន **ព្រះពុទ្ធឃោសាចារ្យ,ព្រះអនុរុទ្ធាចារ្យ** ជាដើម។

ក្នុងព្រះពុទ្ធសាសនា លោកសម្តែងថា មាតាបិតា មានឈ្មោះ៤យ៉ាង ក្នុងនោះមាន ឈ្មោះមួយហៅថា បុព្វាចារ្យ (ជាអាចារ្យទី១)មុនដំបូងបង្អស់។ ហើយនៅក្នុងតួនាទីគ្រូអាចារ្យ និងសិស្សនោះ, អាចារ្យត្រូវមានភារកិច្ច៥យ៉ាង ក្នុងការណែនាំសិស្សឱ្យមានគុណធម៌,សីលធម៌,សមធម៌,សមត្ថភាព, និងចំណេះដឹង។ ដូច្នេះ អាចកំណត់បានថាប្រភព នៃអាចារ្យ នេះពិតជាមានកំណើតមកពីពាក្យថា អ្នកសិក្សា, អ្នកស្រាវជ្រាវ, អ្នកបង្រៀន។ (ធិន ភេន គុណធម៌កសាងជាតិ បោះពុម្ពឆ្នាំ២០០៧ ទំ.២០លើកទី១)។ នៅក្នុងឯកសារព្រះពុទ្ធកិច្ច ៤៥ព្រះវស្សា ភាគទី១ ទំព័រ៩០ បាននិយាយថា:ព្រះនាងមហាបជាបតិគោតមី បានកសាងសំពត់សាដកប្វាយសំពត់ បំពោះព្រះពុទ្ធ

ដោយផ្ទាល់ក្នុងវស្សាទី៥។ក្នុងពិធីនោះ គេមិនឃើញមាន អាចារ្យដឹកនាំទេ គឺមានតែព្រះនាងផ្ទាល់។ ដូច្នេះ អាចារ្យក្នុងទីនេះ គឺព្រះនាងខ្លួនឯងតែម្តង។ ក្រោយពី ការចេញវស្សាបាន ឮដំណឹងថាព្រះពុទ្ធយាងមកកាន់ភទ្ទិយនគរ ដែនអង្គៈ ព្រមដោយភិក្ខុ១២៥០រូប ។ ស្របពេលនោះទ្រង់ឃើញឧបនិស្ស័យ សោតាបត្តិផលរបស់បុគ្គលគឺ មេណ្ឌកសេដ្ឋី,នាងចន្ទបទុម ភរិយាធនញ្ជ័យសេដ្ឋី បុត្រនាងសុមនាទេវី បុត្រប្រសា នាងវិសាខា ចៅស្រីនិងទាសៈឈ្មោះ នាយបុណ្ណៈ ជាដើម។ខណៈនោះមេណ្ឌកសេដ្ឋី ទើបបញ្ជូនចៅស្រីវិសាខាអាយុ៧ឆ្នាំ ទៅយាង ព្រះមកទទួលភត្តាហារ នៅផ្ទះរបស់ខ្លួន។ ន័យនេះ អាចបញ្ជាក់ថា មេណ្ឌកសេដ្ឋី ជាអាចារ្យក្នុងពិធីនោះ មិននរណា ផ្សេងទៀតឡើយ។ (ឯកសារព្រះពុទ្ធកិច្ច ៤៥ ព្រះវស្សាភាគទី១ ទំព័រ ១០៦)។ សរុបសេចក្តីមកទោះបីអនាថបណ្ឌិកសេដ្ឋីក្តី, នាងវិសាខាក្តី, ព្រះសារីបុត្រថ្វាយបង្ហាត់បំពោះព្រះភិក្ខុសង្ឃក្តី,ក៏លោកទាំងនោះ ធ្វើជាអាចារ្យដឹកនាំដោយខ្លួនឯងដែរ។ នៅក្នុងគម្ពីរអភិធម្មត្ថាធិប្បាយរបស់**សម្តេច លី្វ ឯម** ក៏មាននិយាយពី ព្រះសារីបុត្រ ធ្វើជា ព្រះអាចារ្យបង្រៀនព្រះអភិធម្ម ដល់ព្រះភិក្ខុសង្ឃ,ហើយនៅក្នុងពុទ្ធប្រវត្តិ ត្រង់អាចារ្យទោណព្រាហ្មណ៍ បែកធាតុព្រះសម្មាសម្ពុទ្ធ ជាដើម។

**បណ្ឌិតាចារ្យសម័យមហានគរ** (គ.សវ.ទី៩ ដល់១៤) គ.ស.៨០២ ដល់១៣៣៦ មានដូចទៅ៖

**១-បណ្ឌិតសិវសោម**=រស់នៅក្នុងស.វ.ទី៩នៃគ.ស. គឺក្នុងរជ្ជកាលព្រះបាទឥន្ទ្រវរ្ម័នទី១ (គ.ស.៨៧៧ ដល់ ៨៨៩)។

បណ្ឌិតរូបនេះ ជាអ្នកមានចំណេះខាងក្បួនច្បាប់ផ្សេងៗ ក្នុងអក្សរសាស្ត្រនិងមន្តវិជ្ជាគាថាខាងសាសនា(ពិសេសខាងព្រហ្មញ្ញសាសនា)។លោកបាននិពន្ធរឿងមហាភារតៈ និងក្បួនវេយ្យាករណ៍ ព្រមទាំងសិលាចារឹក។

**២-បណ្ឌិតយតិអមរភាវៈ**= ជាអ្នកប្រាជ្ញដ៏សំខាន់មួយរូប ក្នុងរជ្ជកាលព្រះបាទយសោវរ្ម័ន (គ.សវ.ទី៩ និងដើមទី១០ គឺដល់ ៨៨៩ ដល់ ៩០៨)។ ព្រះរាជាទ្រង់សព្វព្រះរាជហឫទ័យ តាំងបណ្ឌិតនេះជាអធិបតី នៃបណ្ឌិតទាំងឡាយ ហើយលើកឱ្យមានឋានៈស័ក្តិជា សង្ឃរាជ លើវត្តឥន្ទ្រាស្រម(ផ្នែកសាសនាព្រាហ្មណ៍)។**បណ្ឌិតយតិអមភោវៈ**បាននិពន្ធសិលាចារឹកទុកនៅភ្នំបាយ័ង្គ។

**៣-បណ្ឌិតទិវាករ**=ជាអ្នប្រាជ្ញឯក ក្នុងសម័យព្រះបាទរាជិន្ទ្រវរ្ម័នទី១ (គ.សវ.១០គឺគ.ស.៩៤៤ដល់៩៦៨)។ បណ្ឌិតរូបនេះ ចេះចារត្រៃវេទស្ទាត់ជំនាញណាស់។ ព្រះមហាក្សត្រសព្វព្រះរាជហឫទ័យ ព្រះរាជទានរាជបុត្រីមួយអង្គនាម(ឥន្ទ្រលក្ស្មី)ឱ្យធ្វើជាភរិយាបណ្ឌិតទិវាករនេះ។

**៤-បណ្ឌិតកវិន្ទ្រៈ**=ជាអ្នកប្រាជ្ញយ៉ាងធំ ក្នុងសម័យរជ្ជកាលព្រះបាទសូរ្យវរ្ម័នទី១ (គ.សវ.ទី១១ គឺគ.ស.១០០ ដល់ ១០៤៩)។ លោកជាអ្នកចេះចាំស្ទាត់នូវគម្ពីរក្បួនខ្នាតផ្សេងៗ ដោយបានឋានៈជា ទីប្រឹក្សា នៃព្រះមហាក្សត្រផ្ទាល់។ លោកបានិពន្ធសិលាចារឹកនៅប្រាសាទខ្នា សម្រាប់សរសើរនូវតេជបារមីរបស់ព្រះបាទសូរ្យវរ្ម័ន ជាក្សត្រសឹកដ៏ក្លាហាន មុះមុតក្នុងចម្បាំង។

**៥-បណ្ឌិតភូបេន្ទ្រៈ**=ជាអ្នកប្រាជ្ញល្បីល្បាញ ក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧ (គ.សវ.១២ និងដើមទី១៣ គឺ គ.ស.១១៦២ ដល់ ១២០១)។

បណ្ឌិតភូបេន្ទ្រៈ ត្រូវបានព្រះមហាក្សត្រតាំងជាអធិបតី លើគណៈអ្នកប្រាជ្ញ និងនាទីជាចៅក្រមល្បី ខាងបំណោះនីតិសាស្ត្រ។

**៦-ព្រះនាងឥន្ទ្រទេវី**=ព្រះនាងជាអគ្គមហេសីទី២ នៃព្រះបាទជ័យវរ្ម័នទី៧ ព្រះនាងជាអគ្គសាវ្ធបត្ថម្ភខាងព្រះពុទ្ធ សាសនា។ព្រះនាងបានកសាងវប្បធម៌ អក្សរសាស្ត្រជាតិ ឱ្យបានបម្រើនល្អតលាស់ខ្លាំងក្នុងសវ.ទី១២និង១៣ នៃគ.ស. ដោយបានបង្កើតឱ្យមានសាលាបាលីជាន់ខ្ពស់ និងបង្កើតវង់ល្ខោន ជាដើម។ ព្រះនាង ត្រូវបានព្រះបាទជ័យវរ្ម័នទី៧ តែងតាំងជា នាយកនៃសាស្ត្រាចារ្យមហាវិទ្យាល័យពុទ្ធសាសនា បំនួន៣គឺ **នគេន្ទ្រ ទុង្គ តិលកោត្តរៈ** និង **នរេន្ទ្រាស្រម** ។ **នគេន្ទ្រ ទុង្គ** គឺជាមហាវិទ្យាល័យពុទ្ធសាសនាទីមួយដែលស្ថាបនានៅក្នុងកម្ពុជា ហើយដែលព្រះនាងឥន្ទ្រទេវី ទ្រង់បង្រៀនស្ត្រីទាំងឡាយ រួមទាំងព្រះមហេសីផង ។ (ព័ត៌មាននេះដកស្រង់ចេញពី សិលាចារឹកនៅប្រាសាទពិមានអាកាស ដែលព្រះឥន្ទ្រទេវីទ្រង់និពន្ធដោយព្រះអង្គឯងផ្ទាល់ ក្នុងកំណាព្យ ជាភាសាសំស្ក្រឹតដ៏រស់រវើកបំនួន១០២ឃ្លាំង)។សូមបញ្ជាក់ថា នៅក្នុងសិលាចារឹក ព្រះនាងឥន្ទ្រទេវី គឺជាក្សត្រមួយអង្គ ដែលពូកែលើសលុបឥតមាននរណាស្មើ ក្នុងផ្នែកវិទ្យាសាស្ត្រនឹងបរមត្ថវិជ្ជា ហើយព្រះរាជាទ្រង់តាំងជា **បរិនាយកាចារ្យ** ក្នុងអារាមព្រះពុទ្ធសាសនាយ៉ាងល្បីល្បាញមួយ។(សក្ក សឺដេស អំពីក្សត្រមួយអង្គក្រុងកម្ពុជាជយវរ្ម័នទី៧ បោះពុម្ពឆ្នាំ១៩៣៥,លោក ជុំ ម៉ៅ បកប្រែ ទំ.២០)។

**៧-បណ្ឌិតយោគីស្វរបណ្ឌិត**=បណ្ឌិតយោគីស្វរបណ្ឌិត ជាគ្រូរបស់ព្រះបាទសូរ្យវរ្ម័ន ទី១(គ.ស.១០០២ ដល់១០៤៩)។ យោគីនេះ បាននិពន្ធ

សិលាចារឹកនៅប្រាសាទតាកែវ(ខេត្តសៀមរាប)គឺនៅក្នុងគោបុរៈ ខាងក្រៅដែលជាសរសរ នៅមេទ្វារខាងត្បូង នៃទ្វារខាងក្នុងទិសខាងកើត។

**៨-បណ្ឌិតសិវាចារ្យ**=បណ្ឌិតសិវាចារ្យ ជាអធិបតីត្រួតពិនិត្យខាងសីលធម៌ ក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៥ (គ.ស.៩៦៨ ដល់ ១០០២)និងព្រះបាទសូរ្យវរ្ម័នទី១ (គ.ស.១០០២ ដល់១០៤៩)។ លោកបណ្ឌិតនេះ បានតែងសិលាចារឹក ជាភាសាសំស្រ្កឹតនៅប្រាសាទតាកែវដែរ គឺសិលាចារឹកនៅគោបុរៈខាងក្នុង។ (លោក លាង ហាប់ អានសិក្សាប្រវត្តិសាស្ត្រខ្មែរឆ្នាំ១៩៦៧ភ្នំពេញ)។

ដូច្នេះ អាចបញ្ជាក់បានថា **បណ្ឌិតាចារ្យ** ទាំងអស់នេះសុទ្ធតែជាអ្នកដឹកនាំពិធីសំខាន់ៗក្នុងព្រះរាជវាំង និងមានតួនាទីរៀបចំទំនៀមទម្លាប់របស់ព្រះមហាក្សត្រ និងមន្ត្រីជាន់ខ្ពស់ក្នុងសម័យនោះ។ ពិសេសបណ្ឌិតទាំងនោះលោកដើរតួនាទី ជាអាចារ្យបង្រៀនផង, ក្នុងការចារសិលាចារឹក និងជាអ្នកផ្ដល់ប្រឹក្សាដល់ព្រះមហាក្សត្រ ក្នុងការដឹកនាំប្រទេសជាតិផង។ សមស្របនឹងពាក្យថាអាចរិយៈអ្នកប្រដៅឬហាត់មារយាទ,អ្នកប្រព្រឹត្តល្អ, អ្នកកាន់ត្រឹមត្រូវ,អ្នកដែលសិស្សត្រូវគោរព,អ្នកធ្វើប្រយោជន៍ដល់សិស្ស, អ្នកបង្រៀនបំណេះគេ,គ្រូ,គ្រូបង្រៀន។

**កំណត់បំណាំះ** សម័យមហានគរ គេហៅពាក្យ **អាចារ្យ** ថា **ព្រះរាជគ្រូ,អ្នករៀបចំពិធី,ព្រះមុនី, ព្រាហ្មណាចារ្យ, រុទ្រាចារ្យ** (ឈ្មោះបណ្ឌិតមួយរូប),**អាចារ្យបុរោហិត, គណាចារ្យ** ឬក៏ **ព្រះអាចារ្យ** ដែលមានបញ្ជាក់ក្នុងសិលាចារឹកស្ដុកកក់ធំជាភាសាសំស្រ្កឹតស្រាប់ ។ ឯសម័យបច្ចុប្បន្ន គេនិយមហៅថា អ្នកអាចារ្យឬលោកអាចារ្យ ឬក៏ ព្រះអាចារ្យ មានន័យថា ជា

អ្នករៀបចំពិធី,អ្នកបង្ហាត់បង្រៀនដូចគ្នា។ (សិលាចារឹកស្តុកកក់ធំជាភាសាសំស្រ្កឹតប្រែសម្រួលដោយសាស្រ្តាចារ្យបណ្ឌិតឡុង-សៀម)។

## ក្នុងគម្ពីរពុទ្ធសាសនា ថា អាចារ្យ មាន ៥ ប្រភេទគឺៈ

**១-បព្វជ្ជាចារ្យ**=អាចារ្យបំបួស គឺភិក្ខុអ្នកបំបួសកុលបុត្រឱ្យបានជាសាមណេរ។

**២-ឧបសម្បទាចារ្យ**= ភិក្ខុអ្នកសូត្រញត្តិចតុត្ថកម្មវាចា ឱ្យសាមណេរបានឧបសម្បទាជាភិក្ខុភាព(លោកគ្រូសូត្រ)។

**៣-ឧទ្ទេសាចារ្យ**=អាចារ្យបង្រៀនបាលីភាសា។

**៤-និស្សយាចារ្យ**=អាចារ្យអ្នកឱ្យនិស្ស័យ គឺភិក្ខុអ្នកទទួលភារៈឱ្យសិស្សនៅអាស្រ័យ នឹងខ្លួនឯងផង(គ្រូទទួល បន្ទុក)។

**៥-ធម្មាចារ្យ**=អាចារ្យអ្នកបង្រៀនធម៌អាថ៌ ឬ បង្រៀនបំណេះវិជ្ជាសិល្បសាស្រ្តផ្សេងៗ(ហៅវិជ្ជាចារ្យឬវិទ្យាចារ្យ, សិប្បាចារ្យឬ សិល្បាចារ្យជាដើម តាមរូបសព្ទបំណេះដែលបង្រៀនក៏បាន។

ពាក្យថា **អាចារ្យ** នេះខ្មែរហៅបានច្រើនយ៉ាងទៅទៀតតាមដំណើរដែលប្រកបហៅ,ដូចជាៈ

**អាចារ្យកម្មដ្ឋាន**=គ្រូបង្រៀនកម្មដ្ឋាន(រាប់ចូលក្នុងធម្មាចារ្យ)។ព្រះកម្មដ្ឋានមាន៤០។ (សូមមើលក្នុងសៀវភៅ បឋមវិបស្សនា សំ-ប៊ុនធឿន ត្រង់ទំព័រទី១៣ ដល់ ១៥ ក្នុងពាក្យថា គោរពព្រះធម្មចារ្យសូមរៀនកម្មដ្ឋាន បោះពុម្ពឆ្នាំ២០០៣)។

**អាចារ្យកាន់ពេលា**=អ្នកដែលពិនិត្យមើល ហើយកំណត់ឫក្សពារពេលល្អ ឱ្យគូស្វាមីភរិយា ក្នុងមង្គលការអាពាហ៍ពិពាហ៍។

**អាចារ្យកោរជុក ឬ អាចារ្យកោរសក់**=អ្នកដែលពិនិត្យមើលឫក្ស ពារហើយកំណត់វេលាឱ្យគេក្នុងមង្គលកោរជុក។

**អាចារ្យបញ្ចុះធាតុ**=អ្នកដែលបេះក្បួនឬក្បួនបញ្ចុះធាតុ។

**អាចារ្យយោគី**=អាចារ្យជាប្រមុខនៃអ្នកភ្លុកទាំង ៤ នាក់ ក្នុងការធ្វើឈាបនកិច្ច ឬ អាចារ្យនាំមុខសព (ខ្មោច) ។ ជាទូទៅគេសម្គាល់បុគ្គលិកលក្ខណៈអាចារ្យយោគី ថាមាន ៤ ប្រការគឺៈ

១-ត្រូវប្រកបដោយធម៌ ៤ ប្រការ ស្ថិតក្នុងសីល៥ ឬ ៨,

២-មានចិត្តមេត្តាអាណិតអាសូរដល់អ្នកទីទាល់ក្រលំបាកខ្វះធន់ធាន កុំឱ្យអាចារ្យយោគីបង្គាប់ តាមក្បួនគឺឱ្យជួយរំលាយសពបុគ្គលយកបុណ្យ,

៣-អលោភោ កុំឱ្យលោភលន់ក្រៅគន្លងធម៌,

៤-ធម្មសណ្ឋាវាចា គឺបេះពោលពាក្យពីរោះ បេះស្រដី ទូន្មានពីរោះប្រដៅអ្នកជំងឺឱ្យមានតម្រេកក្នុងធម៌ ។ បើយោងតាមអានិសង្សរបស់អាចារ្យយោគី ថាមាន៣ប្រការៈ

១-មានអាយុវែង,

២-មានញាតិសន្តាននឹងបរិវារច្រើន,

៣-មានប្រាជ្ញាទិព្វ។

តែបើអាចារ្យយោគី ធ្វើមិនល្អ មិនប្រកបដោយធម៌ទេ នឹងមានទោស ៣ ប្រការៈ

១.មានសេចក្តីគរបាគិន្ទា,

២.កើតជាអ្នកហិនហោចអាប់ឥតប្រាជ្ញា,

៣.មានទ្រព្យសម្បត្តិបានត្រឹមរក្សាទុកឱ្យគេមើលតែប៉ុណ្ណោះ។

(ឯកសាររបស់លោកសាស្ត្រាចារ្យ ញាណ ភឿន និង ម៉ម ផៃ លំអានទំនៀមខ្មែរបុរាណភាគ១ ទំ.១០៤-១០៥ បោះពុម្ពលើកទី៩ឆ្នាំ២០១០)។

**អាចារ្យវត្ត ឬអាចារ្យសម្រាប់វត្ត**= ឧបាសកដែលជាប្រមុខក្នុងការបាត់បែងកិច្ចការផ្សេងៗក្នុងវត្ត (ក្នុងសម័យបុរាណ ហៅ អារាមិក ឬ អារាមិកជន,សម័យបច្ចុប្បន្ននេះ លុះតែមន្ត្រីអ្នករាជការរដ្ឋបាល ក្នុងនាទីយល់ព្រមផង ទើបធ្វើជា អាចារ្យវត្ត បាន)។(វចនានុក្រម សម្តេចព្រះសង្ឃរាជ ជ.ណាត ទំព័រ ១៧២០ បោះពុម្ពលើកទី៥ ឆ្នាំ១៩៦៧)។

## ក.១សង្កេត និង ការស្រាវជ្រាវ ៖

នៅក្នុងចំណែកនៃវ័យរបស់ពួកព្រាហ្មណ៍ គេសង្កេតឃើញ ពួកព្រាហ្មណ៍បានបង្កើតការអប់រំគ្រួសារដោយវិធី ៤ យ៉ាង ក្នុងនោះជីវភាពរបស់គេគឺ មានពាក្យមួយ ហៅថា ព្រហ្មចារ្យ ក្នុងកុមារវ័យ កូនព្រាហ្មណ៍ត្រូវរៀនសូត្រគម្ពីរវេទជាមួយព្រាហ្មណ៍។ ឯ នៅក្នុងលទ្ធិសំខាន់ៗ ក្នុងព្រាហ្មណ៍និយម មានពាក្យមួយ គឺលទ្ធិព្រហ្មចារ្យ ជាលទ្ធិមួយដែលពួកព្រាហ្មណ៍បានបង្កើតឡើង សម្រាប់ឱ្យពួកព្រាហ្មណ៍សំអិតសំអាងចិត្ត បេញបាកកាមទៅបួសជាសមណព្រាហ្មណ៍រស់នៅក្នុងទីស្ងប់ស្ងាត់។(មេរៀន វប្បធម៌ផណ្ណាខ្មែរ សែម សូរ បោះពុម្ពលើកទី១ ឆ្នាំ១៩៧១ ទំ.២០ ដល់២២)។

## ១.១សង្កេតនិងការស្រាវជ្រាវតាមសិលាចារឹកខ្លះៗ ៖

យោងតាម សិលាចារឹកនគរវត្ត លេខ៤-៥ របស់ **អកហ្លួងអភយរាជ** យើងសង្កេតឃើញថា ការធ្វើអំណោយរបស់លោកទោះបីតិចក្តី ច្រើនក្តីនោះការដឹកនាំធ្វើពិធីក្តីគឺលោកខ្លួនឯងជាអ្នកដឹកនាំផ្ទាល់តែម្តងៗដូច្នេះមានន័យ

ថា អាចារ្យនេះ ប្រហែលជាកើតចេញពីអ្នកសិក្សាចេះដឹង,អ្នកសិក្សាស្រាវជ្រាវ ទើបមានបំណេះខាងកិច្ចការនេះ ហើយរៀបចំពិធីខ្លួនឯងតែម្តង។ (វង់ សុធារ៉ា សិលាចារឹកនៃប្រទេសកម្ពុជា សម័យកណ្តាល ភាគ១ បោះពុម្ពឆ្នាំ២០០៩ ទំ.១២៨-១២៩)។

យោងតាមសិលាចារឹក លេខ ៣០ របស់នាងគន្ធ ក៏គេសង្កេតឃើញថា មានសម្តេចព្រះសង្ឃ និងព្រះមហាថេរ និងគ្រហស្ថជាច្រើនរូបបានចូលរួមក្នុងពិធីនោះ។ ដូច្នេះ អាចារ្យដែលដឹកនាំពិធីនោះ គឺជាពួកព្រាហ្មណ៍ឬអ្នកចាស់ទុំក្នុងស្រុករបស់នាងផ្ទាល់ ។ (ដូចខាងលើ ទំ.១៨០)។ សិលាចារឹក នគរវត្តលេខ៣៨របស់ជយនន្ទ គេឃើញថា ការរៀបចំពិធីរបស់លោកមានច្រើនណាស់ ហើយប្រជុំទៅដោយរាជបណ្ឌិត ជាច្រើនទាំងស្តេចសង្ឃនិងគ្រហស្ថ។(ដ.ទំព័រ១៨៥)។ សិលាចារឹក នៅប្រាសាទស្តុកកក់ធំ(គឺមាននិយាយច្រើនអំពីការរៀបចំពិធី)ជាដើម។

**សេចក្តីសន្និដ្ឋានៈ** ប្រវត្តិនិងប្រភព នៃអាចារ្យនេះ គឺពិតជាមានមកយូរយារណាស់មកហើយ។មិនមែនទើបតែកើតមាននៅក្នុងសម័យខាងក្រោយនេះទេ។ ពិសេស អាចារ្យ នេះចេញមក ពីពាក្យថា អ្នកសិក្សា (សិក្ខា), អ្នកបង្រៀនបំណេះគេ,គ្រូ,គ្រូបង្រៀន ហ្នឹងឯង។

**បញ្ហាក់ៈ** ខ្ញុំអ្នកស្រាវជ្រាវ មានសេចក្តីសោកស្តាយជាពន់ពេកបំពោះឯកសារប្រវត្តិអាចារ្យនេះខ្លាំងណាស់ ។ ដោយសារឯកសារ ដែលទាក់ទងនឹងប្រវត្តិនេះ មានការខ្វះខាតជាច្រើន មិនសំបូរដូចឯកសារនានាទេ។ដូច្នេះការស្រាវជ្រាវរបស់ខ្ញុំ ទៅលើចំណុចមួយនេះ គឺពឹងផ្អែកលើឯកសារទាំងស្រុង មិនមានការបញ្ចេញបញ្ចូល តាមទស្សនៈ ឬ តាមការនឹកឃើញខ្លួនឯងឡើយ។បើថ្ងៃណាមួយខ្ញុំបានប្រទះឃើញឯកសារស្តីពី ប្រវត្តិ

អាចារ្យនេះខ្ញុំនឹងរៀបចំបំពេញបន្ថែមឱ្យគ្រប់គ្រាន់ទុកជាឯកសារគោលក្នុងការស្រាវជ្រាវថ្មីមួយតទៅខាងមុខ។

# ឯកសារយោង

១.សម្តេច ជួន-ណាត វចនានុក្រមខ្មែរ ទំព័រ ១៧២០ បោះពុម្ពលើកទី ៥ ឆ្នាំ១៩៦៧។

២.បណ្ឌិត សែម សូរ មេរៀន វប្បធម៌ ឥណ្ឌាខ្មែរ បោះពុម្ពលើកទី១ ឆ្នាំ១៩៧១ ទំ.២០ ដល់២២) កម្ពុជា។

៣.លោក វង់ សុធារ៉ា សិលាចារឹកនៃប្រទេសកម្ពុជា សម័យកណ្តាល១ បោះពុម្ពឆ្នាំ២០០៩ ទំ.១២៨ ដល់ ១២៩) ភ្នំពេញ កម្ពុជា។

៤.បទសម្ភាសន៍ ជាមួយលោកសាស្ត្រាចារ្យ យី ធន់ (អតីតទីប្រឹក្សាក្រសួងធម្មការនិងសាសនា)និងជាអ្នកស្រាវជ្រាវព្រះពុទ្ធសាសនាខ្មែរ កាលពីថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ២០១០។

៥.លោក លាង ហាប់អាន សិក្សាប្រវត្តិសាស្ត្រខ្មែរ សម័យនគរភ្នំ ដល់សម័យឧដុង្គ (ស.វ១ ដល់១៨៥៩) បោះពុម្ពឆ្នាំ ១៩៦៧ រោងពុម្ពតារារស្មី ភ្នំពេញ កម្ពុជា។

៦.ប្រវត្តិព្រះរាជពិធីទ្វាទសមាស ប្រត់ព្រះនង្គ័ល បោះពុម្ពឆ្នាំ២០០៤ ទំ.១៨ ដល់ ១៩។

៧.ឯកសារឧប្បត្តិហេតុនៃព្រះត្រៃបិដកប្រែវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ បោះពុម្ពឆ្នាំ១៩៦៩ ភ្នំពេញ កម្ពុជា។

៨.ព្រះធម្មវិបស្សនា សំ-ប៊ុនធឿន បឋមវិបស្សនា ត្រង់ទំព័រទី១៣ដល់១៥ បោះពុម្ពឆ្នាំ២០០៣)កម្ពុជា។

៩.ភិក្ខុ ង៉ិន-ភេន គុណធម៌កសាងជាតិបោះពុម្ពឆ្នាំ២០០៧ ទំ.២០លើកទី១ប្រទេសបារាំង។

១០.លោកអាចារ្យ គោ ក្រុងព្រៃវែង យោងតាមបទសម្ភាសន៍ របស់អាចារ្យការ ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១០។

១១.សាមណេរ សេម-សុវណ្ណរ័ត្ន ព្រះពុទ្ធកិច្ច ៤៥ ព្រះវស្សា ភាគទី១ បោះពុម្ពព.ស.២៥៤៨ ទំព័រ៩០ ភ្នំពេញ

១២.ព័ត៌មាននេះដកស្រង់បេញពី សិលាចារឹកនៅ ប្រាសាទពិមានអាកាស ដែលព្រះនាងឥន្ទ្រទេវី ទ្រង់និពន្ធដោយ ព្រះអង្គឯងផ្ទាល់ ក្នុងកំណាព្យជាភាសាសំស្ក្រឹតដ៏រស់រវើក បំនួន១០២ ឃ្លាំង)។

១៣.បណ្ឌិត ហេមា គោណតិលកេ ព្រះពុទ្ធសាសនាសិទ្ធិស្ត្រីនិងសិទ្ធិមនុស្ស បោះពុម្ពឆ្នាំ១៩៩៦ កម្ពុជា។

១៤.បណ្ឌិត រស់ បន្ទ្រាបុត្រ ការគ្រប់គ្រងរដ្ឋ នាសម័យមហានគរ (សវ.ទី៩ ដល់ទី១៣ នៃគ.ស.)ទំ.១៥២ បោះពុម្ពឆ្នាំ២០០៤ ភ្នំពេញ កម្ពុជា។

១៥.លោកសាស្ត្រាចរ្យ ញាណ ភឿន និងលោកសាស្ត្រាចារ្យ ម៉ម ផៃ លំអានទំនៀមខ្មែរបុរាណភាគ១ ទំ.១០៤ ដល់ ១០៥ បោះពុម្ពលើកទី៩ ឆ្នាំ២០១០)។

១៦.ព្រះមហា នៅ សាខន ប្រវត្តិសាស្ត្រនៃពុទ្ធសាសនា នៅប្រទេស

ឥណ្ឌា បោះពុម្ពឆ្នាំ១៩៦៤ នៅបាងកក ឆ្នាំ២០០៦លើកទី១នៅភ្នំពេញ ទំព័រ៤៨។
១៧.ភិក្ខុមហា ប៉ាង-ខាត, បាចិកចាវៀងប្រវត្តិសាស្ត្រព្រះពុទ្ធសាសនានៅសាធារណៈរដ្ឋខ្មែរ,ក្រុងបាងកក ព.ស.២៥៣៤។
១៨.សទានុក្រមថៃ ច្បាប់រាជបណ្ឌិត្យស្ថាន (ព.ស. ២៤៩៨-២៥២១) កម្ពុជា ខ្មែរ បម្ប៉ា បេនឡា។
១៩.Encycolopedia, Americana. 1969 ed., s.v. “Angkor”, Cambodia Indochina, Southeast Asia”
២០.Encyclopaedia Britannica. ១៩៦៨ed., s.v. Buddhism” , Cambodia, “India Art”
២១.Hall. D.G.E, A History of South-East Asia. New York: St. Martin’s Press, 1970
២២.Harrison, Brian. South-East Asia, A short History. London: Macmillan & Co., Ltd.,1963.
២៣.Somdech Preah Mhasumedhadhipati. The Governing of the Buddhist Order in Cambodia vesakha Puja 2519, Bangkok 1976, PP. 40-47

២៤.Zago, Marcello. “Contemporary Khmer Buddhism” in Buddhism in the modern world” Edited by Heinrich Dumoulin and John C. Maraldo New York: Macmillan Publishing Co., Inc., 1976.

២៥.ដកស្រង់ពីអត្ថបទស្មារតីខ្មែរ និងព្រះពុទ្ធសាសនា របស់លោកជំទាវបណ្ឌិត ខ្លួត-ធីតា ប្រធានរាជបណ្ឌិត្យសភាកម្ពុជានាយិការងនៃមហាវិទ្យាល័យទស្សនវិជ្ជា (សកលវិទ្យាល័យភូមិន្ទភ្នំពេញ ២)។

២៦.ភិក្ខុ ប៉ាង-ខាត់ ១៩៥៧ ពុទ្ធសាសនា២៥០០, ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ(១៩៥៧)។

២៧.បណ្ឌិត ខ្លួត-ធីតា ការស្វែងយល់អំពីរបត់ព្រះពុទ្ធសាសនានៅក្នុងសង្គមខ្មែរ ២០០២ ទំព័រ ១៣១ ទំព័រ១៣៣។

២៨.លោក យី-ធន់ វត្តអារាមជាមជ្ឈមណ្ឌលវប្បធម៌របស់ប្រជារាស្ត្រខ្មែរ កម្ពុជសុរិយា លេខ៤ ១៩៩៥ ទំព័រ ៤៧។

២៩.ឈឹម-អៀម ការអប់រំរបស់ព្រះពុទ្ធសាសនា កម្ពុជសុរិយា លេខ៣ ១៩៩៦ ទំព័រ១៩ដល់២៥។

៣០.លោក ស៊ក្ស-ស៊ីដេស អំពីក្សត្រមួយអង្គក្រុងកម្ពុជាជយវរ្ម័នទី៧ បោះពុម្ពឆ្នាំ១៩៣៥ ជុំ ម៉ៅ បកប្រែជាខេមរភាសា ទំ.២០) ពុទ្ធសាសនបណ្ឌិត្យ។

៣១.សទ្ទានុក្រម សំស្ក្រឹត ខ្មែរ បារាំង,បណ្ឌិត ពៅ សាវរស,ឆ្នាំ២០១៣, បោះពុម្ពដោយបណ្ណាគារអង្គរ,ប្រទេសកម្ពុជា។

៣២.វចនានុក្រមខ្មែរបាស់ បារាំង អង្លេស, បណ្ឌិត ពៅ សាវរស, ឆ្នាំ ១៩៩២,បោះពុម្ពនៅប្រទេសបារាំង។

៣៣.បទានុក្រម បាលី សំស្ក្រឹត ខ្មែរ,ជិត ជន កិត្តិបណ្ឌិតព្រឹទ្ធសាស្ត្រាចារ្យ
បាលី សំស្ក្រឹត,បោះពុម្ពឆ្នាំ២០១២។

# ឧបសម្ព័ន្ធ

## សិលាចារឹកស្តុកកក់ធំ ជាភាសាសំស្ក្រឹត,សិលាចារឹក ជយនន្ទ,